# សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)
Cambodian Water Supply Association (C.W.A)


## សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់ និងដំឡើងម៉ូទ័របូមចែកចាយទឹកស្អាត និងប្រព័ន្ធទូរបញ្ជាម៉ូទ័រ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) អង្គការយូនីសេហ្វ (UNICEF) និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសេកគង់ ស្ថិតនៅក្នុងភូមិត្រាចទង ឃុំក្រៀមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បាននឹងកំពុងអនុវត្តគម្រោង «**បង្កើននូវភាពធនសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនរស់នៅក្នុងតំបន់ដែលបានរងគ្រោះពីគ្រោះធម្មជាតិ ដែលមិនទាន់មានបណ្តាញទឹកស្អាត**» ក្រោមជំនួយថវិកាពីអង្គការយូនីសេហ្វ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ សមាគមមានកិត្តិយសសូមអញ្ជើញក្រុមហ៊ុន ផ្គត់ផ្គង់ និងមានបទពិសោធន៍ក្នុងការ ដំឡើងម៉ូទ័របូមចែកចាយទឹកស្អាត និងប្រព័ន្ធទូរបញ្ជា ម៉ូទ័រទឹកស្អាត ក្នុងព្រះរាជាណាចក្រកម្ពុជា ដាក់ពាក្យស្នើសុំផ្គត់ផ្គង់ និងផ្តល់សេវាកម្មក្នុងការ ដំឡើងម៉ូទ័របូមចែកចាយទឹកស្អាត និងបរិក្ខាររបស់ប្រព័ន្ធទូរបញ្ជាម៉ូទ័រទឹកស្អាត ជូនដល់ប្រតិបត្តិករទឹកស្អាត ខាងលើដូចមានក្នុងតារាងព័ត៌មាន និងលក្ខខណ្ឌលម្អិតដូចខាងក្រោម៖

| ល.រ | បរិយាយពីសម្ភារ | លក្ខណៈសម្ភារ | ម៉ាក | ចំនួន |
|---|---|---|---|---|
| 1 | ម៉ូទ័របូមចែកចាយទឹកស្អាត | Q=160m$^3$/h, 50hp,( 37kw ), Total heard=50m | ជប៉ុន | 2 |
| 2 | ប្រព័ន្ធទូរបញ្ជាម៉ូទ័រ និងប្រព័ន្ធខ្សែភ្លើង | ប្រព័ន្ធខ្សែភ្លើងសម្រាប់តម្លើង ( Set ) | ជប៉ុន | Set |
| 3 | គ្រឿងតណភ្ជាប់ម៉ូទ័របូមចែកចាយ | គ្រឿងតំណផ្សេងៗសម្រាប់ភ្ជាប់ម៉ូទ័រ( Set ) | ជប៉ុន | Set |

1. រាល់ឯកសារដេញថ្លៃរួមមាន៖ ពាក្យសុំដេញថ្លៃ និងឯកសារភ្ជាប់នានា ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត រួចផ្ញើមកការិយាល័យសមាគម ត្រឹមម៉ោង**១២:០០ថ្ងៃត្រង់**ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០២១។ រាល់ឯកសារដេញថ្លៃទាំងឡាយដែលបានដាក់ក្រោយកាលបរិច្ឆេទ មិនត្រូវបានពិចារណាឡើយ។
2. ក្រុមហ៊ុនដែលទទួលបានជោគជ័យ ត្រូវរៀបចំ ដំឡើងម៉ូទ័របូមចែកចាយទឹកស្អាត និងប្រព័ន្ធទូរបញ្ជា ម៉ូទ័រទឹកស្អាតជូនស្ថានីយផ្គត់ផ្គង់ទឹកស្អាតខាងលើ យ៉ាងយូរបំផុតត្រឹម**ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២**។
3. ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ អាចមកទទួលឯកសារដេញថ្លៃនៅសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដោយឥតគិតថ្លៃ ដែលមានអាសយដ្ឋានដូចរៀបរាប់ខាងក្រោម ឬទាញយកពីគេហទំព័រ www.cwa.org.kh ឬទំព័រហ្វេសប៊ុក Cambodian Water Supply Association និង អ៊ីមែល៖ info@cwa.org.kh។ ***រាល់តម្លៃត្រូវបូកបញ្ចូលពន្ធលើតម្លៃបន្ថែម(VAT) ឬបញ្ជាក់ពីការបង់ពន្ធកាត់ទុក ( Withholding Tax) ក្នុងករណីពុំមាន(VAT)។***
4. ការបើកស្រោមសំបុត្រដេញថ្លៃនឹងត្រូវប្រព្រឹត្តឡើងជាសាធារណៈនៅការិយាល័យសមាគម នា**ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ២:០០រសៀល** ដែលមានអ្នកចូលរួមមកពីតំណាងស្ថានីយផ្គត់ផ្គង់ទឹកស្អាត តំណាង អង្គការយូនីសេហ្វ តំណាងមកពីក្រសួងឧសហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងតំណាងក្រុមហ៊ុនដាក់ដេញថ្លៃ។
5. **អាសយដ្ឋានទំនាក់ទំនង និងដាក់ពាក្យ៖** មជ្ឈមណ្ឌលភ្នំពេញ អគារF ជាន់ទី២ វិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញឬ ទូរស័ព្ទលេខ៖ ០១២ ៤៩៤ ៧៦០ ឬ ០១៧ ៧៩៩ ៣៣៧ ឬ ០៧០ ៧៩៩ ៣៣៧ ឬ ០៩៧៧ ១៧៩ ៩៤៣។ អ៊ីមែល៖ info@cwa.org.kh គេហទំព័រ៖ www.cwa.org.kh